ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ :.....៤៤៣/២១.....ក.ប/ខ.ល

## សារលិខិតជូនពរ

### សូមគោរពជូន សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា និងលោកជំទាវ

*សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់!*

ក្នុងទិវាដ៏សោមនស្សរីករាយ នាឱកាសឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ នេះ តាងនាមថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្នុងនាមខ្ញុំបាទ និងភរិយា ព្រមទាំងក្រុមគ្រួសារ សូមប្រសិទ្ធពរបវរមហាប្រសើរជូន **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានគណបក្សប្រជាជនកម្ពុជា និង**លោកជំទាវ** សូមទទួលបាននូវកម្លាំងខ្លាំងក្លាប្រាជ្ញាឈ្លាសវៃ ជន្មាយុយឺនយូរ និងសម្រេចជោគជ័យដ៏ត្រចះត្រចង់ថ្មីៗបន្ថែមទៀត ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមចំពោះប្រជាជន និងប្រទេសជាតិ។

ឆ្លៀតក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ យើងខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី និងទេវតាឆ្នាំថ្មី ព្រមទាំងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមប្រោសព្រំប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ ជូនដល់ **សម្តេច និងលោកជំទាវ បុត្រា បុត្រី ចៅប្រុស ចៅស្រី** សមប្រកបតែនឹងពុទ្ធពរទាំង៥ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវ** មេត្តាទទួលនូវគារវភក្តីដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

*ថ្ងៃ សុក្រ ១២ រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មេសា ឆ្នាំ២០២១*

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៥